Radio Free Asia

# របាយការណ៍បង្ហាញថាកម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសដែលមានអំពើពុករលួយកម្រិតខ្ពស់

ដោយ យ៉ង ចាន់តារា

2017-01-25




ប្រធានអង្គការតម្លាភាពអន្តរជាតិ (Transparency International) លោក ព្រាប កុល ថ្លែងក្នុងសន្និសីទសារព័ត៌មានសន្ទស្សន៍ការយល់ឃើញពីអំពើពុករលួយសម្រាប់ឆ្នាំ២០១៦ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ នារាជធានីភ្នំពេញ។ RFA/Yang Chandara

RFA/Yang Chandara

អង្គការតម្លាភាពអន្តរជាតិ (Transparency International) រកឃើញថា កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសដែលមានអំពើពុករលួយកម្រិតខ្ពស់នៅលើពិភពលោក។ ការលើកឡើងបែបនេះ ផ្អែកលើរបាយការណ៍សន្ទស្សន៍ការយល់ឃើញពីអំពើពុករលួយសម្រាប់ឆ្នាំ២០១៦ ចេញផ្សាយនៅព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧។

ទោះបីជារដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវកំណែទម្រង់លើវិស័យមួយចំនួនដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយក្ដី ក៏កិច្ចខិតខំប្រឹងប្រែងនេះមិនទាន់អាចផ្លាស់ប្ដូរការយល់ឃើញរបស់អ្នកជំនាញអន្តរជាតិខាងអភិបាលកិច្ច ខាងនីតិរដ្ឋ និងវិស័យធុរកិច្ចបាននៅឡើយ។

សន្ទស្សន៍ការយល់ឃើញពីអំពើពុករលួយក្នុងវិស័យសាធារណៈឆ្នាំ២០១៦ របស់អង្គការតម្លាភាពអន្តរជាតិ បង្ហាញថា កម្ពុជាទទួលបានពិន្ទុ ២១ ស្ថិតក្នុងលេខរៀងទី១៥៦ ក្នុងចំណោមប្រទេស១៧៦។ កម្ពុជាទទួលបានពិន្ទុ ២១ នេះ រយៈពេល ៣ឆ្នាំជាប់គ្នាមកហើយ។

លទ្ធផលនៃសន្ទស្សន៍នេះ បង្ហាញថា កម្ពុជានៅតែជាប្រទេសដែលមានអំពើពុករលួយកម្រិតខ្ពស់ ហើយនៅតែឈរក្នុងចំណាត់ថ្នាក់ទាបបំផុតក្នុងចំណោមប្រទេសសមាជិកអាស៊ាន និងចំណាត់ថ្នាក់ទាបបំផុតលំដាប់ទី៣ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក។

នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា លោក ព្រាប កុល ថ្លែងថា ការលុបបំបាត់អំពើពុករលួយក្នុងប្រព័ន្ធតុលាការគឺជាគន្លឹះដ៏សំខាន់ ដើម្បីឱ្យការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា មានប្រសិទ្ធភាព។ លោកសង្កត់ធ្ងន់ថា នៅពេលការបោះឆ្នោតកាន់តែខិតជិតមកដល់ស្ថាប័នតុលាការកាន់តែរងនូវការរិះគន់ពីគ្រប់មជ្ឈដ្ឋាន ថាអនុវត្តការងារមានចរិតនយោបាយ ដែលធ្វើឱ្យពលរដ្ឋបាត់ទំនុកចិត្ត។ បន្ថែមពីលើនេះ បញ្ហាគ្រួសារនិយម និងបក្ខពួកនិយមនៅតាមស្ថាប័នសាធារណៈនៅមិនទាន់ត្រូវបានដោះស្រាយឡើយ ដែលធ្វើឱ្យកម្ពុជា បន្តស្ថិតក្នុងស្ថានភាពពុករលួយកម្រិតខ្ពស់ដដែល៖ *«បើសិនជាអ្នកប្រព្រឹត្តអំពើពុករលួយ គាត់អាងលុយ គាត់អាងខ្នង ហើយតុលាការ និងប្រព័ន្ធយុត្តិធម៌យើងពុករលួយ ធ្វើម៉េចអាចដាក់ទោសគាត់បាន។ អ៊ីចឹងហើយបានជាវិស័យយុត្តិធម៌ វិស័យតុលាការនេះ គឺជាគន្លឹះមួយ។ ទីពីរ បញ្ហាសេវាសាធារណៈដែលជាបញ្ហាចម្បងរបស់ប្រជាពលរដ្ឋនៅក្នុងការរស់នៅប្រចាំថ្ងៃក៏ជាអាទិភាពដែរ»*។

ឆ្លើយតបនឹងបញ្ហានេះ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ លោក ឱម យ៉ិនទៀង មិនទទួលស្គាល់ការដាក់ពិន្ទុរបស់អង្គការតម្លាភាពអន្តរជាតិឡើយ។ លោកបញ្ជាក់ប្រាប់អាស៊ីសេរី តាមបណ្ដាញសង្គមវាត់ស្អាប់ (WhatsApp) ថា របៀបធ្វើ និងដាក់ពិន្ទុរបស់អង្គការតម្លាភាពអន្តរជាតិ មានចរិតនយោបាយលាបពណ៌ ហើយចំណុចសំខាន់នោះ គឺការដាក់ពិន្ទុរបស់អង្គការអន្តរជាតិមួយនេះនាំមកនូវការបែកបាក់គ្នាដែលផ្ទុយពីគោលការណ៍រួមគ្នាប្រឆាំងអំពើពុករលួយរបស់អង្គការសហប្រជាជាតិ។

នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា លោក ព្រាប កុល ថ្លែងថា ប្រភពទិន្នន័យដែលអង្គការតម្លាភាពបានយកមកសិក្សា គឺជាប្រភពពីស្ថាប័នអន្តរជាតិធំៗដែលមានកេរ្តិ៍ឈ្មោះ ដូចជាធនាគារពិភពលោក និងវេទិកាសេដ្ឋកិច្ចពិភពលោកជាដើម បូករួមនឹងការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងការប្រើវិធីសាស្ត្រស្រាវជ្រាវល្អិតល្អន់ ដែលធ្វើឱ្យការរកឃើញនេះ គឺជាព័ត៌មានដែលអាចជឿទុកចិត្តបាន។

អំពើពុករលួយត្រូវបានអង្គការអន្តរជាតិបែងចែកជា ៦ទម្រង់ គឺការស៊ីសំណូកការកេងប្រវ័ញ្ច ការលួចបន្លំ ការសម្លុតគំរាម បញ្ហាបក្ខពួក ឬគ្រួសារនិយម និងអំពើពុករលួយផ្នែកនយោបាយ។

នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា លោក ព្រាប កុល បារម្ភថា អំពើពុករលួយផ្នែកនយោបាយនឹងកើតមានច្រើននៅកម្ពុជា ក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៦ នៅពេលខាងមុខ។ លោកចង់ឱ្យគណបក្សនយោបាយនីមួយៗបង្ហាញឆន្ទៈច្បាស់លាស់ចំពោះការប្រយុទ្ធប្រឆាំងអំពើពុករលួយ៖ *«យើងនឹងយកចិត្តទុកដាក់លើអំពើពុករលួយនយោបាយ ដូចជាការទិញសន្លឹកឆ្នោតពេលឃោសនា ឬក៏ការប្រើប្រាស់ឥទ្ធិពល អំណាចរដ្ឋដើម្បីបម្រើសកម្មភាពនយោបាយ ដូចជា ការប្រើប្រាស់តួនាទីជាមន្ត្រីរាជការទៅបម្រើបក្សនយោបាយ ដើម្បីឱ្យត្រូវតាមច្បាប់ ហើយទប់ស្កាត់ការទិញសន្លឹកឆ្នោត ការចែកអំណោយ ឬក៏ការផ្តល់នូវការដោះដូរណាមួយ ដែលជារូបភាពពុករលួយនយោបាយ យើងនឹងផ្តោតរឿងហ្នឹង ប៉ុន្តែយើងក៏ធ្វើរឿងដទៃទៀតដែរ ដែលទាក់ទងនឹងរឿងពុករលួយ»*។

សម្រាប់ឆ្នាំ២០១៧ នេះ អង្គការតម្លាភាពអំពាវនាវជាថ្មីម្តងទៀត ដល់រដ្ឋាភិបាលអនុវត្តអនុសាសន៍ដែលធ្លាប់បានលើកឡើងកាលពីពេលមុន។ អនុសាសន៍ទាំងនោះរួមមាន កំណែទម្រង់ប្រព័ន្ធតុលាការ ការបង្កើតច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន វិសោធនកម្មច្បាប់ប្រឆាំងអំពើពុករលួយ ការបង្កើតច្បាប់ការពារសាក្សី និងអ្នករាយការណ៍ បង្កើនការវិនិយោគស្អាតស្អំ ព្រមទាំងដោះស្រាយបញ្ហាបក្ខពួកនិយម និងទំនាស់ផលប្រយោជន៍ក្នុងស្ថាប័នរដ្ឋសាធារណៈ៕

**កំណត់ចំណាំចំពោះអ្នកបញ្ចូលមតិនៅក្នុងអត្ថបទនេះ៖ *ដើម្បីរក្សាសេចក្តីថ្លៃថ្នូរ យើងខ្ញុំនឹងផ្សាយតែមតិណាដែលមិនជេរប្រមាថដល់អ្នកដទៃប៉ុណ្ណោះ។***